# សិល្បៈជាកញ្ចក់ឆ្លុះសង្គម៖ តន្ត្រីក្នុងជីវិតជនជាតិដើមភាគតិច

ទស្សនៈ «សិល្បៈជាកញ្ចក់ឆ្លុះសង្គម» ឆ្លុះបញ្ចាំងពីរបៀបរៀបរយនិងសកម្មភាពសហគមន៍រួមរបស់ជនជាតិ រួមទាំង «ភូមិមូល» ដែលជាទីកន្លែងនិងទីលានដែលគេរស់នៅជួបជុំ ប្រារព្ធពិធីដែលមានរបាំនិងតន្ត្រី ដើម្បីពង្រឹងនូវស្មារតីសហគមន៍និងផលប្រយោជន៍រួម ក៏ដូចជាសុវត្ថិភាពនិងសុខដុមភាពសង្គម។

ពាក់ព័ន្ធនឹងឧបករណ៍និងវង់តន្ត្រី ឧបករណ៍ធ្វើពីឫស្សីនិងឈើ ច្រើនប្រើនៅក្នុងបរិបទក្រៅសាសនា ចំណែកឯឧបករណ៍ធ្វើពីដែកនិងស្ពាន់ មានគងពីរ បី ប្រាំ ប្រាំពីរ ១២ និង ១៣ផ្ទៃ ប្រើនៅក្នុងបរិបទសាសនា។

ទំនាក់ទំនងរវាងបុគ្គលនិងសហគមន៍ទៅនឹងព្រលឹងអារក្ខអ្នកតា គឺជារឿងមួយដ៏សំខាន់ក្នុងការធានាបាននូវសុវត្ថិភាពនិងសុខដុមភាពសង្គម។ នៅក្នុងន័យនេះ ជនជាតិរៀបចំប្រារព្ធ «ពិធីសែនគង» មុននឹងគេយកគងមកសម្តែងនិងផឹកស្រាដឹកនាំដោយមេកន្ទ្រាញ មេភូមិ ឬចាស់ទុំក្នុងសហគមន៍ ដូចយើងបានឃើញនៅក្នុងចំណោមជនជាតិព្រៅនិងការ៉ែតក្នុងខេត្តរតនគិរី។

វង់គងពីរផ្ទៃរបស់ជនជាតិព្រៅ ហៅថា ហ្គងថាច ឬ កាពីងតាក់ម៉ឺត (គងធំ កាពីង = ប្តី, គងតូច តាក់ម៉ឺត = ប្រពន្ធ)។ គេក៏មានតំណមខ្លះក្នុងការប្រើប្រាស់គងនេះ។ គេប្រើគងនេះនៅក្នុងឱកាសផ្សេងៗ ដូចជាអាពាហ៍ពិពាហ៍ សែនភូមិ កាប់ក្របី ផឹកស្រា ឬសពជាដើម។ បញ្ជីបទដែលគេសម្តែងជាមួយវង់គងពីរផ្ទៃមាន៖ តាឡាក់តាវឡា សម្រាប់ឡើងផ្ទះថ្មី កាប់ក្របី និងពិធីផ្សេងៗទៀត, តាកឡាក់ចេញ សម្រាប់ឡើងផ្ទះថ្មី កាប់ក្របី និងពិធីផ្សេងៗទៀត, តាក់ឡូងចិត្ត សម្រាប់ឡើងផ្ទះថ្មី និងអាពាហ៍ពិពាហ៍។

វង់គងប្រាំផ្ទៃរបស់ជនជាតិការ៉ែត មានឈ្មោះថា ហ្គងឈើង ឬហ្គងប៉ាច ឬហ្គងជីង ដែលគេប្រើនៅក្នុងបរិបទផ្សេងៗដែរ ដូចជាពិធីផឹកស្រា អាពាហ៍ពិពាហ៍ និងចំណងមិត្តភាព។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

នៅក្នុងចំណោមជនជាតិព្នងនៃតំបន់តាកុកព្នង ជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ប៉ែកខាងត្បូងសានប្រទេសកម្ពុជា ក៏មានវង់គងមួយចំនួននិងចាប៉ីឃ្មោកខ្សែ៨ ហៅ ហ្គងរីង ដែរ។ នៅកម្ពុជា គេឃើញមានចាប៉ីឃ្មោកនេះនៅក្នុងចំណោមជនជាតិភាគតិចមួយចំនួន ដូចជា៖ ព្នង ហ្គងរីង, ទំពួន ហ្គងទីង, គ្រឹង ជីងរៀង, ប្រាយ ប៉ាសទូង, កាចក់ ហ្គងកាដេះ, និងព្រៅ ប្រួក។ ចាប៉ីឃ្មោកទាំងនេះ សម្តែងដោយបុរសនៅក្រោមពន្លឺព្រះច័ន្ទជាការកែកម្សាន្តក្នុងចំណោមក្រុមបុរសនិងស្ត្រី។

គេសម្តែងវង់គងប្រាំពីរផ្ទៃ ហៅថា ខ្នាសកាក់ខ្នាសយ៉ាង នៅពេលកាប់មាន់ឬក្របី និងផឹកស្រា។ នៅក្នុងចំណោមជនជាតិគ្រឹង គេប្រើវង់គង១២ផ្ទៃ ហៅ ហ្គងជីង (គងញី និងគងឈ្មោល) សម្តែងដោយបុរសសុទ្ធនៅក្នុងពិធីផ្សេងៗ ដូចជាចូលឆ្នាំ សែនព្រលឹង សែនស្រូវទុំ កាប់ក្របី សព ឬក៏គ្រាន់តែជួបជុំគ្នាផឹកស៊ី រាំលេងសប្បាយរីករាយធម្មតា។ ជនជាតិគ្រឹងមិនអាចរស់នៅដោយគ្មានវង់គងឡើយ។ គេតែងតែឮសូរសំឡេងគងនៅក្នុងគ្រប់ការជួបជុំគ្នានិងគ្រប់ពិធីទាំងឡាយ។ ក៏មានន័យថា ជនជាតិគ្រឹងមិនមានតំណមអ្វីពិសេសដែលថាមិនឱ្យប្រើគងទាំងនេះឡើយ។ គេក៏ដឹងថាពិធីនីមួយៗជាពិធីអ្វីទៅតាមបទដែលគេសម្តែង។

របាំជនជាតិលាតត្រដាងពីការរិលជុំនៃភូមិស្ថានរបស់គេ មានការកាប់ឆ្ការនិងដុតចម្ការ ដាំដុះនិងប្រមូលកាត់ ការផ្លាស់ប្តូរលំនៅស្ថានពីភូមិចាស់ទៅនៅភូមិថ្មី ឬរាំវង់ភូមិថ្មី។ ដូច្នេះ យើងក៏អាចសន្មតថាជីវិតជនជាតិភាគតិច ស្ថិតនៅជុំវិញជំនឿអរូបី ពិធី ផឹកស្រា និងគ្រួសារ។ សកម្មភាពសហគមន៍ ឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចសង្គម រួមមានការដាំដុះនិងប្រមូលកាត់ ការសាងសង់ផ្ទះ ឬជីកព្រែកប្រឡាយរួមគ្នា។

ជាមួយគ្នានេះដែរ គឺគេលេងភ្លេងជាក្រុម ដែលជានិមិត្តរូបបង្ហាញពីស្ថានភាពសហគមន៍និងគោលបំណងរួមតែមួយព្រមទាំងសាមគ្គីភាពជាក់ច្បាស់នៅក្នុងបរិបទសង្គម និងវប្បធម៌របស់គេ។ ក៏ដូចគ្នាដែរសហគមន៍ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ តន្ត្រីជនជាតិ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ភាគតិចខាងលើ មានការផ្លាស់ប្ដូរនិងវិវត្តទៅតាមពេលវេលានិងកាលៈទេសៈ ជាពិសេស នៅក្នុងបរិបទ សកលភាវូបនីយកម្ម បន្ទាប់ពីមានការហូរចូលមកនូវវប្បធម៌ប្រជាប្រិយ ទំនាក់ទំនង ជាមួយទីក្រុង លក្ខណៈប្រពៃណីមួយចំនួនមានការប្រែក្លាយនិងបាត់បង់។ យុវវ័យជនជាតិខ្លះ ក៏បោះបង់ចោលនូវទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន ហើយចាប់យកប្រពៃណីនិងវប្បធម៌ថ្មីវិញ។ ជាការពិតណាស់ ដែលគេមានការពិបាកក្នុងជម្រើសរវាងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនិងការថែរក្សាប្រពៃណី ពោលគឺ «ថាស្រួលជាងធ្វើ»។ ជំនួសវង់គងដោយអ៊ិកកាដង់ ឬកាវ៉ាអូខេ ជាឧទាហរណ៍ជាក់ស្ដែងដែលកើតមាននៅក្នុងចំណោមជនជាតិភាគតិច ក៏ដូចជាសង្គមខ្មែរទូទៅដែរ។ ទស្សនៈ ការទទួលយក និងការអនុវត្តលើអត្តបុគ្គល ភាពជាតារា មនុស្សធម៌ទាប និងការធ្វើឲ្យអស់ឬឱនថយនូវភាពជាមនុស្ស បញ្ជាក់ច្បាស់ពីភាពផ្ទុយគ្នាស្រឡះរវាងអតីតកាលនិងបច្ចុប្បន្នកាល បុរាណនិងសម័យ ក្រុមនិងបុគ្គល ព្រមទាំងការសង្កត់ធ្ងន់ទៅលើគំនិតនិងទស្សនៈ «យើង» ជាង «ខ្ញុំ» ក៏ដូចដែលសិល្បៈឆ្លុះសង្គម ដូច្នោះដែរ៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

## ឯកសារយោង

កែវ ណារុំ.

(២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។ ពេជ្រ ទុំក្រវិល.

(២០០៣). *ទស្សនីយភាពកម្ពុជា*. ភ្នំពេញ: រដ្ឋសភាជាតិនៃប្រទេសកម្ពុជា។ មហោស្រពគង់ជនជាតិភាគតិច.

(២០១៨). *រៀបចំដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និង គណៈអភិបាលនៃអភិបាលខេត្តរតនៈគិរី នាទីក្រុងបានលុង ខេត្តរតនៈគិរី*។

Rizzi, Claudia, and Lenaghan. Nick. (January 26-February 8, 1996). “Ethnic Tribes in Spotlight over Land Grab,” *Phnom Penh Post*, 5.

Sam, Sam-Ang, Yun, Khean, and Chhim, Naline. (2010). *Music in the Lives of the Indigenous Ethnic Groups in Northeast Cambodia*. Phnom Penh: PUC Press.

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង